# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

**ខែវិច្ឆិកា - ធ្នូ ឆ្នាំ២០១៨ / November – December 2018**

**មាតិកា**


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប/Executive summary** | **១** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends** | **៣** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់/Consumer price index | ៣ |
| ១.២. វិស័យហិរញ្ញវត្ថុ/Finance | ៤ |
| ១.៣. វិស័យពាណិជ្ជកម្ម/Trade | ៦ |
| ១.៤. ការអនុវត្តថវិកា/Budget execution | ៧ |
| ១.៥. វិស័យវិនិយោគឯកជន/Private investment | ៧ |
| ១.៦. វិស័យទេសចរណ៍/Tourism | ៨ |
| ១.៧. វិស័យសំណង់/Construction | ៨ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ/International commodity prices** | **៩** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ៩ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ៩ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ៩ |
| **៣. ឧបសម្ព័ន្ធ** | **១១** |

## **ខ្លឹមសារសង្ខេប / Executive summary**

**១.** សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញនៅខែធ្នូ បានថយចុះ **0,៥%** ធៀបនឹងខែមុន ប៉ុន្តែកើនឡើង **១,៦%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ស្ថានភាពអតិផរណាក្នុងឆ្នាំ២០១៨នេះ នៅតែបន្តស្ថិតក្នុងកម្រិតល្អប្រសើរ ក្នុងនោះ **អត្រាអតិផរណាមធ្យមប្រចាំឆ្នាំមានប្រមាណ *២,៥%* ពោលគឺ ទាបជាងឆ្នាំ២០១៧ ដែលមានអត្រា *២,៩%* ដោយសារការថមថយកំណើននៃសន្ទស្សន៍ថ្លៃក្រុមទំនិញម្ហូបអាហារ និងសន្ទស្សន៍ថ្លៃក្រុមទំនិញដឹកជញ្ជូន ដែលមានមេគុណប្រមាណជាងពាក់កណ្ដាល (៥៧ភាគរយ) នៃទំហំកន្ត្រកទំនិញសរុប ។**

**២.** គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៨ ការផ្ដល់ឥណទានដោយធនាគារពាណិជ្ជសរុបមានចំនួន ៨២.២៨៩ ប៊ីលានរៀល បានកើនឡើង ១,៨% ធៀបនឹងខែមុន និងបានកើនឡើង ២៣,៣% ធៀបនឹង១ឆ្នាំមុន ក្នុងនោះឥណទានដល់វិស័យសេវាកម្មមានសមាមាត្រ ៥៣,៣% នៃឥណទានសរុប, ឥណទានវិស័យកសិកម្ម ឧស្សាហ៍កម្ម និងសំណង់ ២៤%, ឥណទានរូបវន្តបុគ្គលនិងឥណទានផ្សេងៗ ១៩,៣%, និងឥណទានដល់គ្រឹះស្ថានហិរញ្ញវត្ថុមានសមាមាត្រ ៣,៥% នៃឥណទានសរុបផ្ដល់ដោយធនាគារពាណិជ្ជ។ រីឯ អត្រាការប្រាក់ធនាគារពាណិជ្ជចំពោះកម្ចីជាប្រាក់រៀលមានអត្រា ១១,៤% និងជាប្រាក់ដុល្លារមានអត្រាការប្រាក់ ១១,១%។

រូបិយវត្ថុទូទៅ M2 មានចំនួនប្រមាណ ៨៧,៥ ទ្រីលានរៀល បានកើនឡើង 0,៦% ធៀបនឹងខែមុន និងបានកើនឡើង ២៣,៥% ធៀបនឹងឆ្នាំមុន។ ក្នុងរយៈពេលប្រាំបីឆ្នាំចុងក្រោយនេះ រូបិយវត្ថុទូទៅ M2 មានកំណើនមធ្យមប្រមាណ ២១% ក្នុងមួយឆ្នាំ ក្នុងនោះប្រាក់បញ្ញើជារូបិយប័ណ្ណអន្តរជាតិកើនឡើងប្រមាណ ២២,៣%។

**៣.** ក្នុងឆ្នាំ២០១៨ តម្លៃជួញដូរលើទីផ្សារមូលបត្រកម្ពុជា (CSX) មានចំនួន ២៤,៩ ប៊ីលានរៀល បានកើនឡើងក្នុងកំណើនខ្ពស់ធៀបនឹងឆ្នាំមុនៗ ក្នុងនោះ ឆ្នាំ២០១៧ តម្លៃជួញដូរមានចំនួន ១២,៦ ប៊ីលានរៀល និងតម្លៃជួញដូរក្នុងឆ្នាំ២០១៦ មានចំនួន ១០ ប៊ីលានរៀល។

**៤. ស្ថានភាពពាណិជ្ជកម្មក្នុងរយៈពេល ១២ខែ ឆ្នាំ២០១៨ នៅតែមានភាពរឹងមាំ ក្នុងនោះការនាំចេញសរុបមានទំហំទឹកប្រាក់ប្រមាណ ១២.៧៣៩ លានដុល្លារ បានកើនឡើង ១៤,៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។** ការកើនឡើងនេះគឺដោយសារកំណើននៃការនាំចេញផលិតផលកាត់ដេរនិងស្បែកជើង គ្រឿងបង្គុំរថយន្ត ឈើកែច្នៃនិងក្តារបន្ទះ និងផលិតផលនេសាទនិងផលិតផលកសិកម្មផ្សេងៗទៀត។ ចំណែកឯ **ការនាំចូលសរុបក្នុងរយៈពេល ១២ខែ ឆ្នាំ២០១៨ មានទំហំទឹកប្រាក់ ១៦.៨៧៦ លានដុល្លារ បានកើនឡើង ២៤,០% ។ ការកើនឡើងនេះ គឺដោយសារកំណើននៃការនាំចូលបរិក្ខារសំណង់ ៥៣,៥% វាយនភ័ណ្ឌ ២១,៦% គ្រឿងយន្ត ២៥,៤% និង ប្រេងឥន្ធនៈ ២៦,៨%។**

**៥.** គិតត្រឹមរយៈពេល ១២ខែ ឆ្នាំ២០១៨ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណូលសរុបបានចំនួន **១៩.៧៤៣,១៣** ប៊ីលានរៀល បានកើនឡើង **១៥,៤0%** បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ ដែលក្នុងនោះ ពន្ធប្រយោល ពន្ធពីពាណិជ្ជកម្មក្រៅប្រទេស បានកើនឡើង **២៣,0៥%**, និង **១៩,៩១%** រៀងគ្នា ស្របពេលដែលចំណូលមិនមែនសារពើពន្ធកើនឡើង **៣,៤៣%**។ រីឯ អនុវត្តចំណាយបានចំនួន **២0.៣៦៩,២៧** ប៊ីលានរៀល ដែលក្នុងនោះ ចំណាយចរន្តអនុវត្តបានចំនួន **១៤.២៦៧,0១** ប៊ីលានរៀល ស្មើនឹង **៩៣,៧៥%** នៃច្បាប់ប្រចាំឆ្នាំ ឬបានកើនឡើង **៧,១%** បើធៀបនឹង១២ខែឆ្នាំ២០១៧។

៦. ក្នុងរយៈពេល ១២ខែ ឆ្នាំ២០១៨ គម្រោងវិនិយោគឯកជនសរុបដែលទទួលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានចំនួន ១៤៨ គម្រោង មានទុនវិនិយោគប្រមាណ ៥.៨០៤ លានដុល្លារអាមេរិក ក្នុងនោះ ទុនវិនិយោគប្រមាណ ៤៩% ទៅលើផ្នែកសេវាកម្ម ផ្នែកទេសចរណ៍មាន ២៦% ផ្នែកឧស្សាហកម្មមាន ១៦,៩% និងផ្នែកកសិកម្មមាន ៧,៧%។

៧. រយៈពេល ១២ខែ ឆ្នាំ២០១៨ សំណើសុំសាងសង់សរុបមាន ៣.២៩៤ គម្រោង (ភាគច្រើនជាប្រភេទសំណង់លំនៅដ្ឋាន និងពាណិជ្ជកម្ម) បានថយចុះ ១២៤ គម្រោង ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ក្នុងនោះ សំណង់ប្រភេទលំនៅដ្ឋានមានចំនួន ២.៧៥៦ គម្រោង, សំណង់ប្រភេទពាណិជ្ជកម្មមាន ៣០៤ គម្រោង សំណង់ប្រភេទទេសចរណ៍មាន ១១៥ គម្រោង សំណង់ប្រភេទឧស្សាហកម្មមាន ៧៤ គម្រោង សំណង់ប្រភេទសាធារណៈមាន ៣៧ គម្រោង និងសំណង់ប្រភេទវិនិយោគមាន ៨ គម្រោង។

៨. ក្នុងរយៈពេល ១១ខែ ឆ្នាំ២០១៨ ចំនួនមកដល់នៃភ្ញៀវទេសចរអន្តរជាតិសរុបមានចំនួនប្រមាណ ៥លាន ៤សែននាក់ កើនឡើងប្រមាណ ១១,១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ក្នុងនោះ ភ្ញៀវទេសចរជនជាតិចិននៅតែបន្តនាំមុខគេមានចំនួនប្រមាណជាង ១លាន ៨សែននាក់ ឬស្មើនឹង ៣៣,៥% ធៀបនឹងចំនួនភ្ញៀវទេសចរសរុប (កើនឡើង ៦៩,៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន), ទីពីរ គឺភ្ញៀវទេសចរវៀតណាម ១២,៩% និងបន្តបន្ទាប់ រួមមាន ឡាវ ថៃ កូរ៉េ និងជប៉ុន។

៩. ក្នុងខែធ្នូ ឆ្នាំ២០១៨ ប្រេងឆៅ (Brent) ថ្លៃ ៥៣,៩ដុល្លារ/បារ៉ែល ធ្លាក់ថ្លៃ ៥,៦ដុល្លារ/បារ៉ែល ធៀបនឹងខែមុន។ ទោះបីជាថ្លៃមានការធ្លាក់ចុះយ៉ាងណាក្តី ក៏សង្កេតឃើញថា **ថ្លៃមធ្យមប្រចាំឆ្នាំ២០១៨** នៅតែខ្ពស់នៅឡើយធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៧ ពោលគឺ ខ្ពស់ជាង ២៧,៥% (៧១,៩ដុល្លារ/បារ៉ែល ក្នុងឆ្នាំ២០១៨ និង ៥៥,៧ដុល្លារ/បារ៉ែល ក្នុងឆ្នាំ២០១៧)។

ក្នុងខែធ្នូ ឆ្នាំ២០១៨ **អង្ករនាំចេញរបស់កម្ពុជា (ខូច ៥%)** នៅរក្សាថ្លៃបាន ៤៨០ ដុល្លារ/តោន ចាប់តាំងពីខែកញ្ញាមកធ្វើឱ្យថ្លៃគិតជាមធ្យមឆ្នាំ២០១៨នេះ មានការកើនឡើងធៀបថ្លៃមធ្យមឆ្នាំ២០១៧កន្លងទៅ (៤៨២,៩ ដុល្លារ/តោន នៅឆ្នាំ២០១៨ និង ៤២៦ ដុល្លារ/តោន នៅឆ្នាំ២០១៧)។ រីឯ ថ្លៃអង្ករសថៃជាមធ្យមឆ្នាំនេះ ថ្លៃ៤២៣ ដុល្លារ/តោន បានកើន ៥,២% ធៀបនឹងឆ្នាំ២០១៧ ដោយសារការបញ្ជាទិញបានកើនឡើងជាបន្តបន្ទាប់ ក្រោមការចុះអនុស្សរណៈរវាងសហគ្រិនថៃ និងដៃគូនាំចូលនានា ជាពិសេស ហ្វីលីពីន និងការបញ្ជាទិញអង្ករស ៧០ ពាន់តោន និងអង្ករក្រអូប (Hom Mali) ៥ ពាន់តោន និងចិនបញ្ជាទិញ ៤ពាន់តោន ជាអង្ករក្រអូប។ **អង្ករនាំចេញរបស់វៀតណាម (ខូច ៥%)** ថ្លៃ ៣៨០ ដុល្លារ/តោន បានធ្លាក់ចុះ ២៥ ដុល្លារ/តោន ធៀបនឹងខែមុន ប៉ុន្តែថ្លៃអង្ករសជាមធ្យមឆ្នាំនេះ ថ្លៃ ៤១៩ ដុល្លារ/តោន បានកើន ១០% ធៀបនឹងឆ្នាំ ២០១៧ កន្លងទៅ។

ក្នុងខែធ្នូ ឆ្នាំ២០១៨ កៅស៊ូឆៅស្តង់ដារ TSR20 លើទីផ្សារអាស៊ី ថ្លៃ ១.៣២០ ដុល្លារ/តោន បានធ្លាក់ថ្លៃ ៧,៣% ធៀបនឹងខែមុន ដោយសាររងឥទ្ធិពលពីសង្គ្រាមពាណិជ្ជកម្មរវាងមហាអំណាចសេដ្ឋកិច្ចចិន និងអាមេរិកនៅតែបន្ត ដែលបណ្តាលឱ្យការបញ្ជាទិញកៅស៊ូនៅទីផ្សារចិន និងជប៉ុន សម្រាប់ផ្គត់ផ្គង់ក្នុងសង្វាក់ផលិតកម្មឧស្សាហកម្មមានការថមថយជាបន្តបន្ទាប់។

# ៣. ឧបសម្ព័ន្ធ

## សូចនាករនាំមុខ (Leading Indicators)

**Construction Approval in Nationwide (0000m2)**




Source: Min. LMUC

**Tourist Arrivals ('000 persons)**



Source: Ministry of Tourism

**Total Textile Export (Mn-US$)**




Source: Customs and Excise Dept.

**Import of Gasoline, Steel, Cement ('000T)**




Source: Customs and Excise Dept.

**Rice Prices in Bangkok and Vietnam 2003 = 100**




Source: MEF & Int.

**Crude oil and Gasoline Price, Jan 2003 = 100**




Source: MEF & Int.

# អតិផរណា រូបិយវត្ថុ និងទុនបម្រុងបរទេស (Inflation, M2 and Foreign Reserve)

**Net Foreign Reserve (Mn US$)**




Source: NBC

**Inflation (Montly)**




Source: NIS

**Inflation (Annual)**




Source: NIS

**Inflation of Main Group Items (monthly)**




Source: NIS

**Inflation of main group Items (Year on Year)**




Source: NIS

**Broad Money M2 (Bn KHR)**




Source: NBC

# អត្រាប្តូរប្រាក់ (Exchange Rate)


















# ធនាគារនិងទីផ្សារមូលបត្រ (Banking and Securities Market)


















# ការអនុវត្តថវិកា (Budget)

### ចំណាយបៀវត្ស និង មិនមែនបៀវត្ស ឆ្នាំ ២០១៧-២០១៨




### ចំណាយបៀវត្ស និង មិនមែនបៀវត្ស ឆ្នាំ ២០១៧-២០១៨




### ចំណូលក្នុងប្រទេស និង ពន្ធលើពាណិជ្ជកម្ម ឆ្នាំ ២០១៧-២០១៨




### ចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ឆ្នាំ២០១៧-២០១៨




### ចំណាយចរន្ត និង វិនិយោគឆ្នាំ ២០១៧-២០១៨




### ការដកសាច់ប្រាក់កម្ចីទ្វេភាគី និងពហុភាគី ឆ្នាំ ២០១៧-២០១៨



## វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)


















# វិស័យពាណិជ្ជកម្ម (Trades)


















## <u>កំណត់សម្គាល់</u>

កៅស៊ូ÷

- កៅស៊ូ TSR20: ឬហៅថាកៅស៊ូស្តង់ដារលេខ២០ រួមមានកៅស៊ូ SIR20, SMR20 និងSTR20 គឺសំដៅលើកៅស៊ូធម្មជាតិដែលមានសារធាតុផ្សេងៗទៀត២០%។ កៅស៊ូធម្មជាតិមានច្រើនប្រភេទ ក្នុងនោះកៅស៊ូដែលមានតម្រូវការប្រើប្រាស់ច្រើនជាងគេគឺកៅស៊ូស្តង់ដារ (កៅស៊ូដុំ) និងកៅស៊ូបន្ទះ។ កៅស៊ូ TSR20 ជាប្រភេទកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ ប្រើប្រាស់សម្រាប់ផលិតកម្មកង់ឡាន បំពង់ទីបជ័រ កម្រាលជ័រ ស្បែកជើងនិងអាវភ្លៀងជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាប ហើយងាយលាយបញ្ចូលជាមួយសារធាតុដទៃ ដែលធ្វើឱ្យផលិតផលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំ ធន់និងមិនងាយសឹករិចរិល។ ប្រទេសសំខាន់ៗដែលផលិតកៅស៊ូប្រភេទនេះគឺម៉ាឡេស៊ី ថៃ ឥណ្ឌូណេស៊ី វៀតណាមនិងចិន។
- កៅស៊ូRSS (Ribbed Smoked Sheets) បែងចែកជា៦ប្រភេទគឺ ប្រភេទលេខ 1, 2, 3, 4, 5 និងប្រភេទពិសេស មានពណ៌លឿងនិងវេចខ្ចប់ជាបន្ទះ។ កៅស៊ូប្រភេទ RSS3 ច្រើនផលិតនៅប្រទេសថៃ ឥណ្ឌា និងឥណ្ឌូណេស៊ី ប្រើប្រាស់ជាវត្ថុធាតុសម្រាប់ផលិតសំបកកង់រថយន្ត បំពង់ទីបជ័រ និងស្បែកជើង។ កៅស៊ូប្រភេទនេះប្រើប្រាស់ក្នុងឧស្សាហកម្មផលិតសំបកកង់រថយន្ត និងដែលជាធាតុផ្សំលើស 50% នៃផលិតផល។

ប្រេងឆៅ÷

ប្រេងឆៅ Brent, WTI និង Dubai ជាប្រភេទប្រេងឆៅធុនស្រាល (Light Crude Oil) ដែលមានការទិញលក់ច្រើនជាងគេ និងជាថ្លៃមូលដ្ឋានក្នុងការទិញលក់កិច្ចសន្យាអនាគត (Future Contract)។ ប្រេងឆៅលើទីផ្សារអន្តរជាតិមានលក្ខណៈខុសគ្នាទៅតាមប្រភេទដូចជា÷ ប្រភេទប្រេងBrent ច្រើនផលិតនៅតំបន់សមុទ្រអាត្លង់ទិចខាងជើង, ប្រភេទប្រេងរបស់អាមេរិក WTI (West Texas Intermediate) និងប្រភេទប្រេងរបស់អារ៉ាប់ប៊ីសាអ៊ូឌីត Dubai។ ប្រភេទប្រេងឆៅទាំងបីមានលក្ខណៈខុសគ្នាទៅតាមកម្រិតភាពស្រាល ហើយប្រភេទប្រេងឆៅដែលមានភាពស្រាលជាងគេអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។ API Gravity ត្រូវបានគេប្រើប្រាស់វាស់វែងភាពស្រាលនៃប្រភេទប្រេងឆៅនីមួយៗ។ ប្រភេទប្រេងដែលមានកម្រិត API Gravity កាន់តែខ្ពស់គឺជាប្រភេទប្រេងដែលកាន់តែស្រាល និងអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។

- WTI 40o API
- Brent 38o API
- Dubai 32o API

**រៀបចំដោយ**

**នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច**

**អគ្គនាយកដ្ឋានគោលនយោបាយ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ ០២៣ ៤២៧ ៩១៣, ០៧៧ ៨៨ ៩៩ ៩២/ ០៧៧ ៥៩ ៩៩ ០៣*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*

*កំណត់សម្គាល់÷*

*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។*

*ការផ្សព្វផ្សាយនេះមិនស្តែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*